ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ២៧.៧ សកបយ

ភ្នំពេញ, ថ្ងៃទី២៨ ខែ [illegible] ឆ្នាំ ២០០០

# សេចក្តីជូនដំណឹង

## ស្តីពីសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក

(កម្មករ និយោជិត)

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ ឬ ក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស និងស្ថាប័នទាំងអស់ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា ១ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបអំពីការប្រតិបត្តិ មាត្រា ២១ នៃច្បាប់នេះ ឱ្យបានជ្រាបដូចតទៅ:

១. នៅពេលដែលមានជ្រើសរើសកម្មករនិយោជិតថ្មី ឬ មានទទួលយកកម្មករនិយោជិតដែលធ្លាប់បានធ្វើការងារនៅទីកន្លែងណាមួយ ឬនៅពេលដែលមានកម្មករ និយោជិតឈប់ពីការងារ ឬត្រូវផ្លាស់ឱ្យទៅធ្វើការងារនៅកន្លែងថ្មី ម្ចាស់ឬនាយកក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងស្ថាប័ននីមួយៗ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកជាលាយលក្ខអក្សរ ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលឱ្យធ្វើការងារ ឬបញ្ឈប់ ឬផ្លាស់ចេញពីការងារ ។ ចំពោះសហគ្រាស គ្រឹះស្ថានធ្វើការងារកសិកម្ម រយៈពេលនេះត្រូវបានកំណត់ ៣០ថ្ងៃ ។

២. សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះមិនអនុវត្តទេ ចំពោះ :

- ការងារម្តងម្កាល ដែលមានថិរវេលាជាប់គ្នាមិនលើសពី៣០ ថ្ងៃ (សាមសិបថ្ងៃ)
- ការងារធ្វើឈប់ៗ ដែលថិរវេលាពិតប្រាកដសំរាប់ការងារនេះមិនលើសពី ៩០ថ្ងៃ (កៅសិបថ្ងៃ) នៅក្នុងរយៈពេល ១២ ខែ បន្តបន្ទាប់គ្នា ។

៣. នៅពេលដែលធ្វើបានជាសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិករួចហើយ ម្ចាស់ឬនាយកក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងស្ថាប័ននីមួយៗ ត្រូវយកសេចក្តីប្រកាសជូនដំណឹងនេះទៅចុះបញ្ជិកា នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ចំពោះអ្នកនៅភ្នំពេញ និង នៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗចំពោះអ្នកនៅខេត្តក្រុង ក្នុងរយៈពេលមិនលើសពី ៧ថ្ងៃ ក្រោយពេលដែលបានធ្វើសេចក្តីប្រកាសជូនដំណឹងនេះរួច ។

៤. នៅពេលដាក់ពាក្យស្នើសុំចុះទិដ្ឋាការលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចូល នៃជនបរទេស ឬ ដែលមានជនបរទេស និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ឬស្ថាប័ននីមួយៗត្រូវមានភ្ជាប់ជាមួយសំណើនូវសេចក្តីថតចម្លងលិខិតឆ្លងដែនរបស់សាមីជនបរទេស និង កិច្ចសន្យាការងាររវាងនិយោជក និងសាមីជនបរទេសម្នាក់ៗ ជាភាសាខ្មែរ ឬដែលមានអមដោយភាសាខ្មែរ ។

៥. ចំពោះការប្រព្រឹត្តល្មើសទៅនឹងមាត្រា ២១ នៃច្បាប់ស្តីពីការងារ ដូចដែលបានណែនាំឱ្យអនុវត្តតាមសេចក្តីជូនដំណឹងនេះ នឹងត្រូវទទួលផ្តន្ទាទោសពិន័យ ដូចដែលបានកំណត់នៅក្នុងមាត្រា ៣៦៣ នៃច្បាប់ស្តីពីការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស និងស្ថាប័ន ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា ១ នៃច្បាប់ការងារ នឹងអនុវត្តឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ស្របទៅតាមខ្លឹមសារដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងនេះ ។

អ៊ិត សំហេង

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

"ដើម្បីជ្រាប"

- ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាខេត្តក្រុង "ដើម្បីអនុវត្ត"
- កាលប្បវត្តិ និង ឯកសារ